សប្តាហ៍ទី
52

សាវ័កប៉ុល

សាវ័កប៉ុលបានធ្វើដំណើរទៅទីកន្លែងជាច្រើន ដើម្បីផ្សាយដំណឹងល្អ។ យើងក៏អាចក្លាយជាអ្នកដែលចែកចាយក្តីស្រឡាញ់របស់ព្រះយេស៊ូបានដែរ!

ការតុបតែងផែនទីផ្សាយដំណឹងល្អ

ក្រោយពីបានជឿលើព្រះយេស៊ូ សាវ័កប៉ុលបានធ្វើដំណើរទៅកាន់ប្រទេស និងទីក្រុងជាច្រើន ដើម្បីផ្សាយដំណឹងល្អ។

លោកបានជួយមនុស្សម្នាឱ្យស្គាល់ព្រះយេស៊ូ និងស្រឡាញ់ព្រះជាម្ចាស់។

ទោះបីជាលោកប៉ុលបានជួបការលំបាកជាច្រើនក៏ដោយ ក៏លោកនៅតែបន្តផ្សាយដំណឹងល្អរហូតដល់ទីបញ្ចប់។

យើងក៏អាចចែកចាយក្តីស្រឡាញ់របស់ព្រះយេស៊ូដូចលោកប៉ុលដែរ!

[កិច្ចការ៩: ១៣-២៨]

និកគិតដល់មនុស្សដែលយើងចង់ផ្សាយដំណឹងល្អ រួចគួរពួកគេបញ្ចូលទៅក្នុងផែនទី!



សម្ភារៈ



ក្រដាសព្រីនទម្រង់ផែនទីផ្សាយដំណឹងល្អ



ក្រដាសព្រីនរូបភាពតូចៗសម្រាប់តុបតែង



ហ្វឺតពណ៌



កន្ត្រៃ



ការ

របៀបធ្វើសកម្មភាព

1. រៀបចំក្រដាសព្រីនទម្រង់ផែនទីផ្សាយដំណឹងល្អ។
2. គូររូបមនុស្ស ឬទីកន្លែងដែលយើងចង់ទៅផ្សាយដំណឹងល្អនៅលើផែនទី។
3. កាត់រូបភាពតូចៗសម្រាប់តុបតែងចេញតាមគែម។
4. យកវាទៅបិទ និងតុបតែងនៅលើផែនទី។
5. ផែនទីផ្សាយដំណឹងល្អរបស់យើងរួចរាល់ហើយ! មកអធិស្ឋានទាំងអស់គ្នា!



ការពង្រីកសកម្មភាព

- សាកនឹកគិតដល់ក្រុមគ្រួសារ មិត្តភក្តិ ឬអ្នកជិតខាង ដែលយើងចង់ផ្សាយដំណឹងល្អ។
- ពិភាក្សាអំពីរបៀបដែលយើងអាចផ្សាយដំណឹងល្អនៅតាមទីកន្លែងនីមួយៗ។
- ណែនាំ និងបង្ហាញផែនទីរបស់យើងទៅកាន់មិត្តភក្តិ រួចអធិស្ឋានរួមគ្នា។
- សាកគូររូបភាពបង្ហាញពីរឿងរ៉ាវនៃការផ្សាយដំណឹងល្អនៅក្នុងព្រះវិហារ។

Tip សម្រាប់គ្រូ

- ទុកពេលឱ្យកុមារបង្ហាញពីមនុស្សដែលពួកគេចង់ផ្សាយដំណឹងល្អដល់ ដោយសេរី។
- គ្រូត្រូវព្រីនរូបភាពតូចៗសម្រាប់តុបតែងទុកជាមុន ងាយស្រួលឱ្យកុមារកាត់យកមកប្រើប្រាស់តែម្តង។
- បង្ហាញគំរូទីកន្លែងប្លែកៗជាច្រើន ដើម្បីឱ្យកុមារមានគំនិតក្នុងការគូរ។
- ក្រោយពេលធ្វើរួច សូមចំណាយពេលមើលផែនទីរបស់កុមារម្នាក់ៗ និងអធិស្ឋានរួមគ្នា។

